ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៦៥ សសរ កសក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារចុះស្រាវជ្រាវ និងផ្ទៀងផ្ទាត់ពិន្ទុល័យដីព្រៃ ដែលប្រជាពលរដ្ឋកាន់កាប់អាស្រ័យផលជាក់ស្តែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើជាកម្មសិទ្ធិ នៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៤ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអង្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៩៣ សសរ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា
- យោងលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារចុះស្រាវជ្រាវ និងផ្ទៀងផ្ទាត់ដីព្រៃដែលប្រជាពលរដ្ឋកាន់កាប់ និងអាស្រ័យផលជាក់ស្តែងនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមទី១- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តកំពង់ស្ពឺ**

១.លោក កង គឹមលី — អនុប្រធាននាយកដ្ឋានអភិវឌ្ឍចម្ការព្រៃឈើ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ

២.លោក ហេង គ្រឹះស្នា — នាយអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រ នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី២- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ និងខេត្តកោះកុង**

១.លោក យន សារ៉េត — អនុប្រធានរដ្ឋបាលព្រៃឈើ

**ក្រុមទី៣- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង**

១.លោក គីម សុបុណ្យ — អនុប្រធាននាយកដ្ឋានអភិវឌ្ឍចម្ការព្រៃឈើ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី៤- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តបាត់ដំបង និងខេត្តប៉ៃលិន**

១.លោក ឡុង រត្តនៈកុមារ — អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី៥- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តសៀមរាប**

១.លោក ឯម មុន្នី — នាយរងអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី៦- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ**

១.លោក ចាន់ សុវត្ថិភាព — អនុប្រធានរដ្ឋបាលព្រៃឈើ

២.លោក លី ម៉េងស៊ាង — ប្រធាននាយកដ្ឋានអភិវឌ្ឍចម្ការព្រៃឈើ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី៧- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ**

១.លោក ទៀង ដាវីដ — អនុប្រធាននាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី៨- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តព្រះវិហារ**

១.លោក អ៊ិត ភក្រ្តា — ប្រធានការិយាល័យពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច នៃនាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់

**ក្រុមទី៩- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តកំពង់ធំ**

១.លោក គីប ញាតា — នាយអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី១០- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ**

១.លោក សៀ វ៉ា — អនុប្រធានរដ្ឋបាលព្រៃឈើ

**ក្រុមទី១១- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តកណ្តាល**

១.លោក សួន សុវណ្ណ — ប្រធាននាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ នៃរដ្ឋបាលព្រៃឈើ

២.លោក កែវ សុផល — នាយរងអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ

**ក្រុមទី១២- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តព្រៃវែង និងខេត្តស្វាយរៀង**

១.លោក ឱម ម៉ាក់ធារី — នាយអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ

២.លោក ប៉ក់ ជាលី — អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី១៣- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តក្រចេះ**

១.លោក ហែម សារាវុធ — ប្រធានការិយាល័យកិច្ចការព្រៃឈើ នៃនាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

**ក្រុមទី១៤- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង**

១.លោក អ៊ឹង ប៉ូលរតនៈ — អនុប្រធាននាយកដ្ឋានអភិវឌ្ឍចម្ការព្រៃឈើ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ

**ក្រុមទី១៥- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី**

១.លោក លី ម៉េងស៊ាង ប្រធាននាយកដ្ឋានអភិវឌ្ឍចម្ការព្រៃជាំ និងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ

ក្រុមទី១៦- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តតាកែវ និងខេត្តកែប

១.លោក ច័ន្ទ ប៊ុណ្ណិកា អនុប្រធានរដ្ឋបាលព្រៃឈើ

ក្រុមទី១៧- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តរតនគិរី

១.លោក យ៉ុន យុវរិទ្ធ អនុប្រធាននាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ នៃរដ្ឋបាលព្រៃឈើ

ក្រុមទី១៨- ទទួលភារកិច្ចអនុវត្តក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់

១.លោក ឡុង ប៊ុង ប្រធានការិយាល័យ នៃរដ្ឋបាលព្រៃឈើ

**ប្រការ ២.-**

ក្រុមការងារចុះស្រាវជ្រាវ និងផ្ទៀងផ្ទាត់ដីព្រៃដែលប្រជាពលរដ្ឋកាន់កាប់ និងអាស្រ័យផលជាក់ស្តែងនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ចុះអនុវត្តដោយផ្ទាល់ សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តនីមួយៗ លើការប្រមូលផ្តុំចងក្រងទិន្នន័យដែលមានស្រាប់ពាក់ព័ន្ធនឹងកិរិយានៃការកាន់កាប់ដីព្រៃឈើ
- ចុះធ្វើការស្រាវជ្រាវ ផ្ទៀងផ្ទាត់ទិន្នន័យដីព្រៃឈើដែលប្រជាពលរដ្ឋកាន់កាប់ និងអាស្រ័យផលជាក់ស្តែង
- រៀបចំកសាងផែនទីបង្ហាញលើទីតាំងកាន់កាប់ដីព្រៃជាក់ស្តែង
- រៀបចំរបាយការណ៍ពិស្តារជូនអគ្គលេខាធិការដ្ឋានប្រតិបត្តិនៃគណៈកម្មាធិការជាតិ ដើម្បីធ្វើការបូកសរុប និងមានចំណាត់ការបន្ត
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានអគ្គលេខាធិការដ្ឋានប្រតិបត្តិនៃគណៈកម្មាធិការជាតិប្រគល់ជូន។

**ប្រការ ៣.-**

ក្រុមការងារខាងលើ អាចជ្រើសរើសសមាជិកបំពេញបន្ថែមតាមតម្រូវការចាំបាច់ក្នុងពេលអនុវត្តជាក់ស្តែង។

**ប្រការ ៤.-**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គលេខាធិការប្រតិបត្តិ ប្រធានអង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**និងជាប្រធានគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីកាត់យកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ